# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

ថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តតារាងនៃការសន្យាពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជា និងវិធានជាក់លាក់សម្រាប់ផលិតផល តាមនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់អាស៊ានឆ្នាំ២០១២ (AHTN 2012) ក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ " RCEP "

យោងតាមព្រះរាជក្រមលេខ នស/រកម/១០២១/០១០ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២១ និងលិខិតលេខ ៥៨៤ សហវ.អគប ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជន និងភាគីពាក់ពន្ធទាំងអស់ឱ្យបានជ្រាបថា កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) រវាងប្រទេសកម្ពុជា និងប្រទេសសមាជិកដទៃទៀត ត្រូវបានចូលជាធរមាននៅ**<u>ថ្ងៃទី០១ ខែមករា ឆ្នាំ២០២២</u>** ស្របតាមមាត្រា ២០.៦ កថាខណ្ឌ ២ នៃកិច្ចព្រមព្រៀងនេះ។ ក្នុងន័យនេះ ទំនិញនាំចូលទាំងឡាយណា ដែលមានដើមកំណើតអនុលោមតាមបញ្ញត្តិ ស្តីពីវិធានដើមកំណើត (រួមទាំងវិធានជាក់លាក់សម្រាប់ផលិតផលក្នុងឧបសម្ព័ន្ធ ៣.ក) នៅបណ្តាប្រទេសជាសមាជិកនៃកិច្ចព្រមព្រៀងខាងលើ អាចទទួលបានប្រព្រឹត្តកម្មអនុគ្រោះពន្ធតាមតារាងនៃការសន្យាពន្ធគយរបស់ព្រះរាជាណាចក្រកម្ពុជាតាម AHTN 2012 ជាឧបសម្ព័ន្ធ ១ នៃកិច្ចព្រមព្រៀង RCEP។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងធុរជនពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តប្រកបដោយប្រសិទ្ធភាព។

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**<u>ព័ត៌មានលម្អិតសូមទំនាក់ទំនង៖</u>**

- ការិយាល័យដើមកំណើតទំនិញ
  - លេខទូរស័ព្ទ៖ ០១២ ៥០៥ ០៧៨/ ០៩២ ៨៦៦ ៦៧៩
  - អ៊ីម៉ែល៖ roo@customs.gov.kh
- ការិយាល័យពាណិជ្ជកម្មសេរី
  - លេខទូរស័ព្ទ៖ ០១២ ៨១៤ ៩៥០/ ០១៧ ៩១៩ ៩៤៥
  - អ៊ីម៉ែល៖ international-affairs@customs.gov.kh

**<u>ដើម្បីទាញយកតារាងកម្មវិធី សូមចូលទៅកាន់ ៖</u>**

https://customs.gov.kh/publications/4190-asean-fta

អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh